**ព្រឹត្តិបត្រព័ត៌មាន** **ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥**

# ធនាគារ មេយប៊ែង ដាក់បង្ហាញនូវការផ្តល់ជូន បទពិសោធន៍ធនាគារបែបទាន់សម័យ

**ភ្នំពេញ ថ្ងៃទី៥ ធ្នូ ២០២៥** — ធនាគារ មេយប៊ែង នាថ្ងៃនេះបានដាក់បង្ហាញនូវការផ្តល់ជូនជំនាន់ក្រោយរបស់ខ្លួន ដែលផ្តោតលើបទពិសោធន៍ធនាគារបែបទាន់សម័យនៅធនាគារ មេយប៊ែង សាខាទឹកថ្លា ដោយមានការបើកសម្ពោធនូវ **កាតឥណពន្ធវីសា ធនាគារ មេយប៊ែង Manchester United** ថ្មី ដែលមានរចនាបទទាន់សម័យសម្រាប់អ្នកគាំទ្រ និងការដាក់សម្ពោធនូវ**មុខងារផ្តល់រង្វាន់ថ្មី**នៅលើកម្មវិធី M2U KH ដែលមានឈ្មោះថា៖ «**Tap, Track, Win**» ដែលត្រូវបានរចនាឡើង ដើម្បីបង្កើនភាពងាយស្រួលសម្រាប់ការរស់នៅប្រចាំថ្ងៃ។

ដោយសារតែស្ថិតនៅក្នុងតំបន់កំពុងអភិវឌ្ឍខ្លាំង នៃរាជធានីភ្នំពេញ **ធនាគារ មេយប៊ែង សាខាទឹកថ្លា** ដើរតួជាចំណុចប្រសព្វមួយដ៏សំខាន់ សម្រាប់ដំណើរការ នៃប្រតិបត្តិការធនាគារប្រចាំថ្ងៃ និងកិច្ចពិភាក្សាអាជីវកម្មតូចធំនានា។ ការរចនាបទ នៃផ្ទៃខាងក្នុងរបស់សាខានេះ ត្រូវបានរចនាឡើងថ្មី ដោយយកលំនាំតាមសិល្បៈល្វែនស្បែក ដែលមានបរិយាកាសស្រទន់ កក់ក្តៅ និងមានការរៀបចំផ្ទៃខាងក្នុង ដែលអាចជួយសម្រួលដល់ការពិភាក្សាយោបល់ជាមួយអតិថិជនមកគ្រប់មជ្ឈដ្ឋាន និងការធ្វើប្រតិបត្តិការធនាគារបានយ៉ាងឆាប់រហ័ស និងងាយស្រួល។ ស្របពេលដែលតំបន់នេះកំពុងប្រែក្លាយទៅជាទីប្រជុំជនថ្មី ដែលប្រមូលផ្តុំទៅដោយអ្នកដឹកនាំ និងអ្នកជំនាញជំនាន់ក្រោយនោះ វត្តមានរបស់**ធនាគារ មេយប៊ែង** នៅតំបន់ទឹកថ្លា បានផ្តល់ទំនុកចិត្តដល់អតិថិជនកាន់តែខ្លាំង ដើម្បីផ្សារភ្ជាប់ជាមួយសហគមន៍ឲ្យកាន់តែល្អប្រសើរបានថែមមួយកម្រិតទៀត។

ថ្លែងនៅក្នុងព្រឹត្តិការណ៍នេះ លោក **វ័ត្ន សោភ័ណ** នាយកប្រតិបត្តិ និងនាយកប្រចាំប្រទេស នៃធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី បានគូសបញ្ជាក់ពីសារៈសំខាន់ជាយុទ្ធសាស្រ្ត នៃទិសដៅនេះថា៖ «ធនាគារ មេយប៊ែង សាខាទឹកថ្លា ត្រូវបានទទួលស្គាល់ជាយូរមកហើយថា ជាចំណុចទំនាក់ទំនងសម្រាប់ការពិភាក្សាអាជីវកម្មសំខាន់ៗ និងការតភ្ជាប់ទំនាក់ទំនងជាមួយអតិថិជន។ នៅពេលអ្នកដឹកនាំ និងម្ចាស់អាជីវកម្មជំនាន់ក្រោយ ចាប់ផ្តើមបន្តស្នាដៃ និងសមិទ្ធិផលរបស់ក្រុមគ្រួសាររបស់ពួកគាត់ យើងក៏ត្រូវចាប់ផ្តើមអភិវឌ្ឍនូវសេវាកម្មធនាគាររបស់យើងឲ្យមានភាពទាន់សម័យ និងប្រកបដោយវិជ្ជាជីវៈខ្ពស់ ដើម្បីឲ្យសមស្របទៅតាមបែបបទ នៃការរស់នៅសម័យថ្មី។ ទាំងនេះបានឆ្លុះបញ្ចាំងពីយុទ្ធសាស្រ្តដ៏ទូលំទូលាយរបស់យើង ក្នុងការផ្តល់ជូននូវបទពិសោធន៍ដែលងាយស្រួល ទំនើប និងសម្រាប់អតិថិជនគ្រប់មជ្ឈដ្ឋាន។ វាស្របជាមួយនឹងចក្ខុវិស័យរយៈពេលវែងរបស់**ធនាគារ មេយប៊ែង** ក្នុងការផ្តល់**សេវាហិរញ្ញវត្ថុប្រកបដោយអរិយ្យភាព** និងក្នុងការគាំទ្រដល់ទិដ្ឋភាពហិរញ្ញវត្ថុដែលកំពុងវិវត្តន៍របស់ប្រទេសកម្ពុជាផងដែរ។»

**កាតឥណពន្ធ របស់ធនាគារ មេយប៊ែង Manchester United** ថ្មី ត្រូវបានរចនាឡើងសម្រាប់អតិថិជនដែលយល់ច្បាស់អំពីភាពក្លៀវក្លា ស្មារតីកីឡា ភាពជឿជាក់ និងអត្តសញ្ញាណជាសកលរបស់ក្លឹបបាល់ទាត់ **Manchester United**។ ក្រៅពីការរចនាបែបទំនើបនេះ កាតនេះបានផ្សារភ្ជាប់ជាមួយស្មារតីកីឡា និងបានផ្តល់ជូននូវឯកសិទ្ធិ និងអត្ថប្រយោជន៍ជាច្រើនបំផុតមួយ ដែលមាននៅក្នុងប្រទេសកម្ពុជា។ ម្ចាស់កាតឥណពន្ធនេះ អាចរីករាយជាមួយ៖

- ការបញ្ចុះតម្លៃ **រហូតដល់ ១៥%** លើសំបុត្រយន្តហោះពី **Malaysia Airlines**
- ការបញ្ចុះតម្លៃលើការទិញទំនិញពី **Official Manchester United Online Store**
- អត្ថប្រយោជន៍ជាច្រើនផ្សេងៗទៀត ដែលផ្តល់ជូនដោយធនាគារ មេយប៊ែង ដូចជាការបញ្ចុះតម្លៃ និងកម្មវិធីប្រូម៉ូសិននានា

អតិថិជន ក៏មានឱកាសឈ្នះរង្វាន់ សម្រាប់**បទពិសោធន៍អ្នកគាំទ្រ Manchester United ដ៏អស្ចារ្យ** ដែលផ្តល់នូវការចូលរួមទស្សនាការប្រកួតផ្ទាល់ និងពេលវេលាដែលមិនអាចបំភ្លេចបាននៅកីឡដ្ឋាន **Old Trafford**។ ការផ្តល់ជូននេះ ត្រូវបានធ្វើឡើងម្តងទៀត បន្ទាប់ពីការផ្តល់ជូននូវបទពិសោធន៍ **Manchester United** របស់**ធនាគារ មេយប៊ែង** កាលពីដើមឆ្នាំនេះ ដែលអ្នកឈ្នះរង្វាន់ពីប្រទេសកម្ពុជាទទួលបានបដិសណ្ឋារកិច្ចជាពិសេស នៅកីឡដ្ឋាន **Old Trafford** ដែលជាដំណើរមួយដែលមិនអាចបំភ្លេចបាន។ ទាំងនេះបានបង្ហាញពីការប្តេជ្ញាចិត្តរបស់**ធនាគារ មេយប៊ែង** ក្នុងការផ្សារភ្ជាប់អតិថិជនជាមួយនឹងបទពិសោធន៍សកលលំដាប់ពិភពលោក។

ទន្ទឹមនឹងការសម្ពោធកាតដែលមានរូវរាងថ្មីនេះ **ធនាគារ មេយប៊ែង** បានដាក់សម្ពោធនូវមុខងារ «**Tap, Track, Win**» ដែលជាកម្មវិធីផ្តល់រង្វាន់ឌីជីថលនៅក្នុងកម្មវិធី **M2U KH**។ លក្ខណៈពិសេសនេះ អនុញ្ញាតឱ្យអតិថិជនទទួលបានអត្ថប្រយោជន៍ រាល់ការធ្វើប្រតិបត្តិការឌីជីថលទូទៅដូចជា៖ ការបញ្ចូលទឹកប្រាក់ទូរស័ព្ទ ការទូទាត់វិក្កយបត្រ ការផ្ទេរប្រាក់ និងការទូទាត់ **QR** ជាមួយកម្មវិធី M2U KH។ ទាំងនេះបានបញ្ជាក់ពីការផ្តោតសំខាន់ ទៅលើការពង្រឹងលើសេវាធនាគារឌីជីថលរបស់ធនាគារ មេយប៊ែង ដែលពោរពេញដោយភាពសាមញ្ញ រលូន និងផ្តល់រង្វាន់។

លោក **ឌុក សារ៉ាក់** នាយក នៃនាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមន៍ នៃធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី បានមានប្រសាសន៍ថា៖ «កាតឥណពន្ធ **Manchester United** ថ្មីនេះ ឆ្លុះបញ្ចាំងពីការបន្តប្តេជ្ញាចិត្តរបស់យើងចំពោះការផ្តល់ជូន ដែលស្របទៅតាមការរស់នៅសម័យថ្មី ខណៈពេលដែលមុខងារ «**Tap, Track, Win**» បានរួមចំណែក ធ្វើឲ្យការប្រើប្រាស់នូវសេវាកម្មឌីជីថលប្រចាំថ្ងៃសម្រាប់អតិថិជនរបស់យើងកាន់តែមានភាពរីករាយ។ ការនាំមកជូនទាំងពីរនេះ បានផ្តល់ជូននូវភាពងាយស្រួល រង្វាន់ និងការផ្សារភ្ជាប់ដែលឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍ និងទម្លាប់របស់របស់ប្រជាជនកម្ពុជានាសម័យទំនើប។»

នៅក្នុងកម្មវិធីនេះផងដែរ អតិថិជនរបស់យើងបានចូលរួមក្នុងការសាកល្បងប្រើប្រាស់នូវសេវាកម្មឌីជីថលដោយផ្ទាល់ ដែលរួមមាន៖ ការបញ្ចូលទឹកប្រាក់តាមទូរស័ព្ទ និងការទូទាត់ **QR** ដែលមានរង្វាន់ភ្លាមៗ។ ទាំងនេះបានបញ្ជាក់ពីសេវាធនាគារសម័យទំនើបដែលមានភាពរលូន និងរីករាយ ដែល ផ្តល់ជូនដោយធនាគារ មេយប៊ែង។ ការដាក់បង្ហាញនូវការផ្តល់ជូនទាំងនេះ នៅ**ធនាគារ មេយប៊ែង សាខាទឹកថ្លា** បានបង្ហាញអំពីជំហរ នៃការប្តេជ្ញាចិត្តរបស់យើង ក្នុងការធ្វើឱ្យសេវាធនាគារកាន់តែមានភាពងាយស្រួល ប្រកបដោយភាពច្នៃប្រឌិត និងសមស្របទៅតាមការរីកចម្រើនរបស់សហគមន៍ក្នុងទីប្រជុំជននៅប្រទេសកម្ពុជា។